**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**
Committee For Free And Fair Elections in Cambodia (COMFREL)

# សេចក្តីជូនដំណឹង
# ស្តីពី
# សិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តតាកែវ

*ភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១*

គណៈកម្មាធិការខុមហ្វ្រែលមានកិត្តិយសសូមគោរពអញ្ជើញ និងជម្រាបដល់បណ្តាប្រព័ន្ធផ្សព្វផ្សាយជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកមេត្តាជ្រាបថា គណៈកម្មាធិការខុមហ្វ្រែលដោយសហការ ជាមួយអង្គការ សមាគមមួយចំនួនក្នុងខេត្តតាកែវ នឹងរៀបចំធ្វើវេទិកាម្ចាស់ឆ្នោតក្នុង **ការវាយតម្លៃលទ្ធផលនៃការបំពេញ/អនុវត្តលក្ខខណ្ឌសន្ទស្សន៍ក្នុងមណ្ឌលតាកែវតាមពេលវេលាដូចខាងក្រោម:**

**<u>ទីកន្លែង:</u>** ទីស្នាក់ការអង្គការអាដហុកខេត្តតាកែវ (ស្ថិតនៅសង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ) នៅជិតមន្ទីរសុខាភិបាល តាមបណ្តោយផ្លូវជាតិលេខ ២ ។

**<u>កាលបរិច្ឆេទ:</u>** ថ្ងៃអង្គារ ទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ វេលាម៉ោង ៨.១៥ព្រឹក ដល់ ៣.៣០ រសៀល

វេទិកាម្ចាស់ឆ្នោតនេះត្រូវបានរៀបចំឡើងជាសកម្មភាពបន្ត និងពិនិត្យមើលលទ្ធផលនៃការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍ក្នុងមណ្ឌលនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់នៅក្នុងសិក្ខាសាលាក្នុងមណ្ឌលរបស់ខ្លួនកាលពីឆ្នាំ ២០០៩។

វេទិកានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដូចតទៅ:

- ឱ្យប្រជាពលរដ្ឋចូលរួមក្នុងសកម្មភាពតាមដាននិងវាយតម្លៃពីសមិទ្ធផលការងាររបស់មន្ត្រីជាប់ឆ្នោតទាំង ថ្នាក់ជាតិ និងថ្នាក់ខេត្តទៅលើលក្ខខណ្ឌសន្ទស្សន៍ក្នុងមណ្ឌលរបស់ខ្លួនតាមរយៈការផ្តល់ជាពិន្ទុ
- បន្តផ្សព្វផ្សាយពីលទ្ធផលនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពដល់ម្ចាស់ឆ្នោតនៅមណ្ឌលដែលមានរៀបចំវេទិកា
- ផ្តល់របាយការណ៍ស្តីពីការរីកចំរើនការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៅមណ្ឌលនីមួយៗដល់សាធារណៈជន អាជ្ញាធរខេត្ត និងមន្ត្រីជាប់ឆ្នោត។

*សូមអរគុណ! សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **០១២ ៦៥ ៤៩ ៥០***